សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់
ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
៨ ធ្នូ ២០១៤

- **សូមគោរព ឯកឧត្តម ពេជ្រ វាសនា នាយកមជ្ឈមណ្ឌលសេវាបច្ចេកទេសធនធានទឹក និងឧតុនិយម!**
- **សូមគោរព លោក អ៊ុម វិបុល ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម!**
- **សូមគោរព លោក ប៊ុន ហួ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវ!**
- **សូមគោរព លោក គឹម សាវុធ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តស្វាយរៀង!**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនបីរួមមាន "គម្រោងស្តារប្រព័ន្ធស្រោចស្រពត្រពាំងកណ្តាលក្នុងខេត្តកំពង់ចាម គម្រោងជួសជុលទំនប់ដើមថ្កូវក្នុងខេត្តតាកែវ និងគម្រោងជួសជុលប្រព័ន្ធធារាសាស្ត្រធ្លកកំបុតក្នុងខេត្តស្វាយរៀង" ។

គម្រោងទាំងនេះ ដែលយើងទើបតែបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅអភិវឌ្ឍវិស័យកសិកម្ម។ យើងទទួលស្គាល់ថាវិស័យកសិកម្ម គឺជាវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា វិស័យកសិកម្ម គឺជាវិស័យធំជាងគេក្នុងប្រទេសកម្ពុជាដែលមានកំលាំងពលកម្មជាង៦០% ហើយយើងជឿជាក់ថាការអភិវឌ្ឍន៍វិស័យនេះ គឺជាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការបង្កើនប្រាក់ចំណូលនៅតាមតំបន់ជនបទផងដែរ។

គម្រោងទីមួយមានថវិកាសរុប១០៣,០២៤ដុល្លារអាមេរិក គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកចំការលើ ខេត្តកំពង់ចាម។ គម្រោងនេះរួមមាន ការស្តារប្រឡាយមេប្រវែង៣,០០០ម៉ែត្រ និងជួសជុលសំណង់ស្ទាក់ទឹក១កន្លែង សាងសង់សំណង់ស្ទាក់ទឹកថ្មី២កន្លែង និងសាងសង់សំណង់បញ្ចូលទឹកថ្មី២កន្លែង។ យើងរំពឹងថាប្រជាជនប្រមាណ២,១៨២នាក់ ក្នុងតំបន់នឹងទទួលបានទឹកស្រោចស្រពទាន់ពេលវេលា បន្ទាប់ពីការបញ្ចប់គម្រោងនេះ។

គម្រោងទីពីរ មានថវិកាសរុប ១០១,៣៥៥ដុល្លារអាមេរិក គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកគិរីវង់ ខេត្តតាកែវ។ គម្រោងនេះរួមមាន ការស្តារទំនប់មួយកន្លែងដែលមានប្រវែង ៣៦០ម៉ែត្រ និងស្តារប្រឡាយរងមួយខ្សែប្រវែង១,២៩០ម៉ែត្រ សង់សំណង់បង្ហៀរទឹកមួយកន្លែងប្រវែង១៥ម៉ែត្រ និងជួសជុលសំណង់បញ្ចេញទឹក១កន្លែង និងសំណង់បញ្ចូលទឹក១កន្លែង។ យើងរំពឹងថាប្រជាជនប្រមាណ ៣,០២៥នាក់ ក្នុងតំបន់នឹងទទួលបានទឹកស្រោចស្រពទាន់ពេលវេលា បន្ទាប់ពីការបញ្ចប់គម្រោងនេះ ។

គម្រោងទីបីមានថវិកាសរុប ១០២,០៦៣ដុល្លារអាមេរិកគឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកចន្ទ្រាខេត្តស្វាយរៀង។ គម្រោងនេះរួមមាន ការស្តារទំនប់មួយកន្លែងដែលមានប្រវែង១,៣៥០ម៉ែត្រ។ យើងរំពឹងថាប្រជាជនប្រមាណ១,៧៩០នាក់ ក្នុងតំបន់នឹងទទួលបានទឹកស្រោចស្រពទាន់ពេលវេលា បន្ទាប់ពីការបញ្ចប់គម្រោងនេះ។

រដ្ឋាភិបាលជប៉ុន បាននិងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា តាមរយៈការគាំទ្រដល់គម្រោងអភិវឌ្ឍជាច្រើន។ គម្រោងក្នុងវិស័យកសិកម្មទាំងនោះរួមមាន ការជួសជុលប្រព័ន្ធធារាសាស្ត្រ និងការផ្ទេរបច្ចេកទេសនៃការដាំដុះជាដើម។ គម្រោងទាំងបីនេះ ធ្វើឡើងតាមគោលការណ៍នៃយុទ្ធសាស្ត្រ ផ្តល់ជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្តល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថា គម្រោងទាំងបីនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងថែទាំយ៉ាងត្រឹមត្រូវ ដើម្បីអោយប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅរួច។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងទាំងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណសម្រាប់ការយកចិត្តទុកដាក់ស្តាប់!